**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ

លេខៈ...០០៥...ព.រ.ក

# សេចក្តីសម្រេចរួម

## ស្តីពី

## ការបង្កើតបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ សម្រាប់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

**ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលទ្ធផលបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២នៃព្រឹទ្ធសភា នាសម័យប្រជុំលើកទី១ នីតិកាលទី២ កាលពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានឃើញលទ្ធផលនៃសម័យប្រជុំលើកទី៤នីតិកាលទី៣នៃរដ្ឋសភាកាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៧/២៥៦ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិបីឆ្នាំ លើកទី៤
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានឃើញសេចក្តីសម្រេចរួមលេខ ០១ ពរក ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ...

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-** ត្រូវបានបង្កើតបេឡាសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិនៅក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា និង អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាគុណប្រយោជន៍ជូនដល់អ្នករាជការនៃអគ្គលេខាធិការដ្ឋានទាំងបី ដែលចូលនិវត្តន៍ ឬ បាត់បង់សម្បទាវិជ្ជាជីវៈ ព្រមទាំងអ្នកកំពុងរស់នៅក្នុងបន្ទុករបស់អ្នកទាំងនោះ ។

អគ្គលេខាធិការ អគ្គលេខាធិការរង ដែលកំពុងកាន់តំណែងនៅអគ្គលេខាធិការដ្ឋាននៃស្ថាប័នទាំងបី អាចសុំចូលនិវត្តន៍នៅអគ្គលេខាធិការដ្ឋានសាមីបាន ប៉ុន្តែសាមីជនត្រូវបង់ភាគទានចូលបេឡាសោធននិវត្តន៍ ។

**មាត្រា២.-** បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ជាអង្គភាពមួយបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ននីមួយៗស្របតាមសេចក្តីសម្រេចនេះ ។

**មាត្រា៣.-** បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈជាអង្គភាពមានស្វ័យភាពផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាអង្គភាពមួយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋាននីមួយៗ ។

**មាត្រា៤.-** បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈគ្រប់គ្រងដោយអង្គភាពមួយដែលស្ថិតក្រោមការត្រួតពិនិត្យរបស់គណៈកម្មការមួយ ដឹកនាំដោយអគ្គលេខាធិការនីមួយៗ ។

## ជំពូកទី ២

## បេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

**មាត្រា៥.-** អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈមានសមាសភាព : ប្រធាន អនុប្រធាន បេឡាករ និង បុគ្គលិក ជាអ្នករាជការនៃអគ្គលេខាធិការដ្ឋាននីមួយៗ ។

**មាត្រា៦.-** អ្នករាជការទាំងអស់នៃក្រុមនីតិប្បញ្ញត្តិត្រូវចូលជាសមាជិកនៃបេឡាសោធននិវត្តន៍ និង បេឡាបាត់បង់សម្បទាវិជ្ជាជីវៈនៅតាមអគ្គលេខាធិការដ្ឋាននីមួយៗ ។

**មាត្រា៧.-** អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ មានភារកិច្ចដូចខាងក្រោម :

១-ស្រាវជ្រាវ និងរៀបចំបទប្បញ្ញត្តិសម្រាប់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

២- រៀបចំផែនការចំណូល-ចំណាយថវិកាប្រចាំឆ្នាំសម្រាប់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

៣- ប្រមូលភាគទានពីសមាជិក ទទួលថវិកាឧបត្ថម្ភពីរាជរដ្ឋាភិបាល និង ទទួលជំនួយពីប្រភពផ្សេងៗ ទៀត

៤- ចាត់ចែង និង គ្រប់គ្រងការវិនិយោគ

៥- ចាត់ចែង គ្រប់គ្រង វាយតម្លៃ និង បើកផ្តល់សម្រាប់ការចំណាយបន្ទាប់បន្សំតាមការកំណត់

៦- រៀបចំរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ និង ប្រចាំឆ្នាំជូនគណៈកម្មការត្រួតពិនិត្យបេឡា និងអគ្គលេខាធិការ

៧- រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំជូនគណៈកម្មការត្រួតពិនិត្យបេឡា និង អគ្គលេខាធិការ ។

## ជំពូកទី ៣
## គណៈកម្មការត្រួតពិនិត្យ

**មាត្រា៨.-** គណៈកម្មការត្រួតពិនិត្យមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- តំណាងអគ្គលេខាធិការ | ១ រូប | ប្រធាន |
| ២- តំណាងអង្គភាពគ្រប់គ្រងបុគ្គលិក | ១ រូប | អនុប្រធាន |
| ៣- ប្រធានបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ | ១ រូប | សមាជិកអចិន្ត្រៃយ៍ |
| ៤- តំណាងអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| ៥- តំណាងអ្នករាជការ | ១ រូប | សមាជិក |

គណៈកម្មការនេះតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន និងមានអាណត្តិ ៣ឆ្នាំ ។

**មាត្រា៩.-** គណៈកម្មការត្រួតពិនិត្យមានបេសកកម្មតម្រង់ទិស និង ត្រួតពិនិត្យដំណើរប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ។

ក្នុងក្របខ័ណ្ឌបេសកកម្មនេះ គណៈកម្មការមានភារកិច្ចដូចតទៅ :

១- ពិនិត្យ និង សម្រេចលើគម្រោងចំណូល-ចំណាយថវិកាប្រចាំឆ្នាំរបស់បេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

២- ពិនិត្យ និង សម្រេចពីទម្រង់បែបបទការងារនៃបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

៣- កំណត់ និង សម្រេចចំនួនក្របខ័ណ្ឌបុគ្គលិកសម្រាប់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

៤- សម្រេចអំពីកិច្ចសន្យាស្តីពីលទ្ធកម្មសាធារណៈនៃបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

៥- កំណត់កម្មវិធី និង ផែនការវិនិយោគមូលនិធិនៃបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

៦- ត្រួតពិនិត្យ និង វាយតម្លៃនូវការចំណាយបន្ទាប់បន្សំតាមការកំណត់

៧- ពិនិត្យ និង សម្រេចលើរបាយការណ៍ប្រចាំឆ្នាំស្តីពីការគ្រប់គ្រងចំណូល និង ចំណាយមូលនិធិរបស់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ។

រាល់ការសម្រេចរបស់គណៈកម្មការត្រួតពិនិត្យ ត្រូវបញ្ជូនតាមឋានានុក្រមទៅប្រធានស្ថាប័នរបស់ខ្លួន ដើម្បីសម្រេចជាចុងក្រោយ ។

**មាត្រា១០.-** សមាជិកគណៈកម្មការត្រួតពិនិត្យ ត្រូវបានជ្រើសរើសក្នុងចំណោមអ្នករាជការដែលសកម្មមានអតីតភាពការងារយ៉ាងតិច ៥ ឆ្នាំ មានបទពិសោធន៍ការងារ មានសមត្ថភាពក្នុងវិស័យគ្រប់គ្រង វិស័យសេដ្ឋកិច្ច វិស័យសង្គមកិច្ច ឬ វិស័យនីតិសាស្ត្រ ។

សមាជិកគណៈកម្មការត្រួតពិនិត្យជាតំណាងអ្នករាជការត្រូវជ្រើសរើសដោយការបោះឆ្នោត ដែលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋាន។

គណៈកម្មការត្រួតពិនិត្យត្រូវបើកអង្គប្រជុំយ៉ាងតិច ១ដង ក្នុងរយៈពេល ៣ខែ ។ ទោះជាមានការកំណត់ដូច្នេះក្តី គណៈកម្មការត្រួតពិនិត្យអាចបើកអង្គប្រជុំបានគ្រប់ពេលអាស្រ័យដោយមានការចាំបាច់ ឬ តាមការអញ្ជើញរបស់ប្រធាន ឬ តាមសេចក្តីស្នើពីសមាជិកលើសពី ៥០ % ។

កិច្ចប្រជុំរបស់គណៈកម្មការត្រួតពិនិត្យ អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី ៥០% ។ សមាជិកគណៈកម្មការ មិនអាចឱ្យគេជំនួសបានទេ ។ ករណីក្វរ៉ុមមិនគ្រប់ អង្គប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយ ដើម្បីពិភាក្សារបៀបវារៈដដែល ។ ការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវឱ្យមានក្វរ៉ុមគ្រប់ឡើយ ហើយរាល់ការសម្រេចនៃការប្រជុំទុកជាបានការ ។

# ជំពូកទី ៤
# ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា១១.-** អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អនុវត្តការងារគណនេយ្យស្របតាមគោលការណ៍គណនេយ្យសាធារណៈ និង បែបបទនានាដែលកំណត់ដោយប្រធានស្ថាប័នទីមួយៗ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំដដែល ។

របាយការណ៍គ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវដាក់ជូនប្រធានស្ថាប័នទីមួយៗសម្រេចក្នុងអំឡុង ១៥ ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចរបស់គណៈកម្មការត្រួតពិនិត្យ ។

**មាត្រា១២.-** រៀងរាល់ឆ្នាំ នៅដើមខែតុលា គណៈកម្មការត្រួតពិនិត្យត្រូវផ្តល់ការយល់ព្រមលើកម្មវិធីអភិវឌ្ឍន៍ និងគម្រោងថវិកាប្រចាំឆ្នាំរបស់អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ តាមសេចក្តីស្នើរបស់ប្រធាន ហើយបញ្ជូនគម្រោងនេះ ដើម្បីសុំការយល់ព្រមពីប្រធានស្ថាប័នទីមួយៗ ។

**មាត្រា១៣.-** ធនធានបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ បានមកពី :

- រដ្ឋឧបត្ថម្ភ ៧% នៃបៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗរបស់អ្នករាជការ
- ភាគទានចំនួន ៦% នៃបៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗរបស់អ្នករាជការ
- អំណោយមានបណ្តាំដោយសប្បុរសជននានា និង អំណោយពីប្រភពផ្សេងៗ
- ការប្រាក់ និង ប្រាក់ចំណេញដែលបានមកពីថវិកាវិនិយោគរបស់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ។

**មាត្រា១៤.-** ការចំណាយរបស់បេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ មានដូចខាងក្រោម :

- ប្រាក់សោធនិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ
- ប្រាក់ឧបត្ថមមរណភាពនៃនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ
- ប្រាក់វិភាជន៍គ្រួសារប្រចាំខែនៃសពនិវត្តជន និង ជនបាត់បង់វិជ្ជាជីវៈ
- ប្រាក់ឧបត្ថម្ភពេលបុណ្យចូលឆ្នាំខ្មែរ និង ពេលបុណ្យភ្ជុំបិណ្ឌ
- ចំណាយបន្ទាប់បន្សំសម្រាប់ការងាររដ្ឋបាល
- ចំណាយលើការវិនិយោគ ។

## ជំពូកទី ៥
## របបសោធននិវត្តន៍

**មាត្រា១៥.-** អ្នករាជការទាំងពីរភេទអាចទទួលរបបសោធននិវត្តន៍ប្រចាំខែបាន លុះត្រាតែបំពេញតាមល័ក្ខខ័ណ្ឌ ដូចបានចែងក្នុងជំពូកទី ៩ ស្តីពីការចូលនិវត្តន៍នៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៦.-** ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនម្នាក់ៗមានប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗ ។

ប្រាក់បៀវត្សមូលដ្ឋានមានចែងក្នុងមាត្រា ១៧ និង មាត្រា ១៨ នៃសេចក្តីសម្រេចនេះ និង ប្រាក់បំណាច់ផ្សេងៗត្រូវកំណត់ត្រឹម ៨០% នៃប្រាក់បំណាច់ផ្សេងៗចុងក្រោយ ។

ចំពោះប្រាក់ឧបត្ថម្ភកូនអាចផ្តល់ជូនអាយុក្រោម ១៨ឆ្នាំ និង ចាប់ពីអាយុ ១៨ឆ្នាំ ដល់ ២១ឆ្នាំ ត្រូវមានលិខិតបញ្ជាក់ពីគ្រឹះស្ថានសិក្សា ។

**មាត្រា១៧.-** និវត្តជនត្រូវទទួលបានប្រាក់សោធននិវត្តន៍អតីតភាពស្មើនឹង ៨០% នៃប្រាក់បៀវត្សមូលដ្ឋានរបស់សាមីខ្លួនលុះត្រាតែបានបំពេញការងារយ៉ាងតិច ៣០ ឆ្នាំ ។

ប្រាក់សោធននិវត្តន៍អតីតភាពនេះត្រូវអនុវត្តតាមករណីដូចខាងក្រោម :

- អ្នករាជការដល់អាយុចូលនិវត្តន៍ និង មានអតីតភាពការងារ ៣០ ឆ្នាំ យ៉ាងតិច
- អ្នករាជការដែលមានអតីតភាពការងារ ៣០ឆ្នាំ ឡើងទៅ ហើយបានស្ម័គ្រចិត្តសុំចូលនិវត្តន៍មុនអាយុចូលនិវត្តន៍ ។

ចំពោះអ្នករាជការដែលមានអតីតភាពការងារគ្រប់ ៣០ ឆ្នាំឡើងទៅ មិនត្រូវកាត់ប្រាក់សម្រាប់ចូលនិវត្តន៍ទៀតឡើយ ។

**មាត្រា១៨.-** និវត្តជនត្រូវទទួលបានប្រាក់សោធនសមាមាត្រ គឺប្រាក់សោធននិវត្តន៍អប្បបរមាស្មើនឹង ៦០% នៃបៀវត្សមូលដ្ឋានរបស់សាមីខ្លួន លុះត្រាតែបានបំពេញការងារក្នុងចន្លោះពី ២០ ឆ្នាំ ដល់ក្រោម ៣០ ឆ្នាំ ។ បើនិវត្តជនមានអតីតភាពការងារលើសពី ២០ឆ្នាំឡើងទៅ ត្រូវបានទទួលប្រាក់សមាមាត្របន្ថែម ១%ក្នុង ៦ ខែ លើបៀវត្សមូលដ្ឋានរបស់សាមីខ្លួនទៀត ។ ប្រាក់សមាមាត្រនេះ គិតតាមករណី ២យ៉ាងដូចខាងក្រោម :

១- មិនត្រូវខ្ពស់ជាងប្រាក់សោធននិវត្តន៍អតីតភាព ៨០% ឡើយ

២- មិនត្រូវទាបជាងប្រាក់បៀវត្សមូលដ្ឋានអប្បបរមាប្រចាំខែនៃឋានន្តរសក្តិថ្នាក់ដំបូងរបស់សាមីខ្លួនឡើយ ។

**មាត្រា១៩.-** និវត្តជនដូចមានចែងក្នុងមាត្រា១៧ និង មាត្រា១៨នៃសេចក្តីសម្រេចនេះត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់នៅគ្រាដំបូងនៃការចូលនិវត្តន៍ ដែលមានទឹកប្រាក់ស្មើនឹងបៀវត្សប្រចាំខែចុងក្រោយគុណ នឹង ៨ ។ ប្រាក់ឧបត្ថម្ភនេះជាបន្ទុករបស់រដ្ឋ ។

**មាត្រា២០.-** អ្នករាជការដែលដល់អាយុចូលនិវត្តន៍ ប៉ុន្តែមានអតីតភាពការងារតិចជាង ២០ឆ្នាំ មិនត្រូវផ្តល់ប្រាក់សោធននិវត្តន៍ឡើយ ។ក្នុងករណីនេះ រដ្ឋត្រូវផ្តល់ប្រាក់ឧបត្ថម្ភម្តងគត់ដោយគណនាតាមរូបមន្តដូចខាងក្រោម :

- អតីតភាពការងារចាប់ពី ៣ឆ្នាំចុះ ត្រូវទទួលប្រាក់ឧបត្ថម្ភស្មើនឹងបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួនគុណនឹង៥ ព្រមទាំងបានទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡាផងដែរ ។
- អតីតភាពការងារលើសពី៣ ដល់៥ឆ្នាំ ត្រូវទទួលប្រាក់ឧបត្ថម្ភស្មើនឹងបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួនគុណនឹង ១០ ព្រមទាំងបានទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡាផងដែរ ។
- អតីតភាពការងារលើសពី៥ឆ្នាំដល់ក្រោម ២០ឆ្នាំ ត្រូវទទួលប្រាក់ឧបត្ថម្ភបន្ថែមស្មើនឹងបៀវត្សប្រចាំខែចុងក្រោយគុណនឹង ១០ ព្រមទាំងប្រាក់សមាមាត្របន្ថែមស្មើនឹងបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួន ១ខែ សម្រាប់ ១ឆ្នាំ ( ប៉ុន្តែប្រាក់សមាមាត្របន្ថែមនេះ មិនត្រូវលើសពីបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួនគុណនឹង ១៤ ទេ ) និង ទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡាផងដែរ ។

## ជំពូកទី៦
## របបសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

**មាត្រា២១.-** អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ ហើយមានអតីតភាពការងារចាប់ពី ២០ឆ្នាំ រហូតដល់ក្រោម ៣០ឆ្នាំ ហើយពុំគ្រប់អាយុចូលនិវត្តន៍ មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍សមាមាត្រ និង ប្រាក់ឧបត្ថម្ភផ្សេងៗ ដូចមានចែងក្នុងមាត្រា ១៦ មាត្រា ១៨ និង មាត្រា១៩ នៃសេចក្តីសម្រេចរួមនេះ ។

**មាត្រា២២.-** អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ ហើយមានអតីតភាពការងារក្រោម ២០ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ដែលមានទឹកប្រាក់ស្មើនឹងបៀវត្សប្រចាំខែគុណនឹង ១០ ព្រមទាំងប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡាផងដែរ ។

## ជំពូកទី៧
## វិធីអតីតភាពការងារ

**មាត្រា២៣.-** របៀបគណនាអតីតភាពការងាររបស់អ្នករាជការ ត្រូវបានកំណត់ដូចខាងក្រោម :

រយៈពេលបម្រើការងាររួមនៃអ្នករាជការ គឺជារយៈពេលបម្រើការងារក្នុងក្របខ័ណ្ឌរដ្ឋគ្រប់របបសង្គម ។ ដោយឡែកចំពោះអ្នករាជការដែលធ្លាប់បានបម្រើការងាររដ្ឋមុនឆ្នាំ១៩៧៥ ហើយពុំបានបម្រើការងារក្នុងរបបប៉ុលពត ក៏ត្រូវបានគិតបន្ថែមរយៈពេលបម្រើការងារ ៣ឆ្នាំ ៨ ខែ និង ២០ថ្ងៃថែមទៀតដែរ ។

រយៈពេលបម្រើការងារនៃអ្នករាជការរួមមាន :

- រយៈពេលបម្រើការងាររដ្ឋនៅតាមក្រសួង ស្ថាប័ននានា គិតទាំងរយៈពេលកម្មសិក្សាផងដែរ
- រយៈពេលបណ្តុះបណ្តាលមុខវិជ្ជាជីវៈក្នុង ឬ ក្រៅប្រទេសក្នុងក្របខ័ណ្ឌរដ្ឋ
- រយៈពេលដែលរដ្ឋចាត់អោយទៅបម្រើការងារក្រៅប្រទេស
- រយៈពេលឃាត់ ឬ ឃុំខ្លួនតែក្រោយមករកឃើញថាគ្មានកំហុស
- រយៈពេលបម្រើការងារ ឬ ជាប់កាតព្វកិច្ចក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ និង នគរបាលជាតិ
- រយៈពេលដែលទទួលតំណែងជាអ្នកនយោបាយ ឬ ស្ថិតក្រៅក្របខ័ណ្ឌដើម ។

មិនត្រូវចាត់ទុកជារយៈពេលបម្រើការងារគឺរយៈពេលត្រូវបានអនុញ្ញាតអោយឈប់ទំនេរដោយមិនទទួលប្រាក់បៀវត្ស ។

រយៈពេលបំពេញការងាររបស់អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈត្រូវគណនាដូចនិវត្តជនដែរ ។

ចំពោះរយៈពេលការងារចាប់ពី ១៦ថ្ងៃឡើងទៅ ត្រូវគិតបញ្ចូលថាស្មើនឹង១ខែ ហើយបើលើសពី៦ខែ ឡើងទៅត្រូវគិតបញ្ចូលថាស្មើនឹង ១ឆ្នាំ ។

## ជំពូកទី៨
## បទប្បញ្ញត្តិដោយឡែក

**មាត្រា២៤.-** និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈទទួលប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ ស្មើនឹង ៥០% នៃប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌរបស់អ្នករាជការក្នុងមុខតំណែង ។

**មាត្រា២៥.-** នៅពេលនិវត្តជនទទួលមរណភាពអង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវផ្តល់ប្រាក់ឧបត្ថម្ភមួយលើកស្មើនឹងប្រាក់សោធននិវត្តន៍ប្រចាំខែរបស់សាមីខ្លួនគុណនឹង ១២ ជូនគ្រួសារនៃសព និង ប្រាក់ ១.២០០.០០០៛ (មួយលានពីរសែនរៀលគត់ ) ដើម្បីធ្វើបុណ្យតាមប្រពៃណី ។ ដោយឡែកចំពោះភរិយានៃសពត្រូវបានបន្តទទួលប្រាក់ឧបត្ថម្ភប្រចាំខែរហូតដល់ពេលគាត់ស្លាប់ ឬ មានប្តីថ្មី ។ ចំណែកកូនរបស់សព ត្រូវទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ដូចកូននៃសពមន្ត្រីរាជការ រហូតដល់អាយុក្រោម ១៨ឆ្នាំ និងចាប់ពីអាយុ ១៨ឆ្នាំ ដល់ ២១ឆ្នាំ ដែលមានលិខិតបញ្ជាក់ពីគ្រឹះស្ថានសិក្សា ។

ក្នុងករណីសពពុំមានឪពុកម្តាយ សហព័ទ្ធ ឬ សាច់សារលោហិត ប្រាក់ឧបត្ថម្ភគ្រួសារសពចំនួន ១២ខែដែលចែងក្នុងវាក្យខ័ណ្ឌខាងលើ និង ប្រាក់ឧបត្ថម្ភចំនួន ១.២០០.០០០ ៛ (មួយលានពីរសែនរៀលគត់ ) ត្រូវប្រើប្រាស់ដោយអង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ដើម្បីធ្វើបុណ្យតាមប្រពៃណី ។

អ្នករាជការដែលទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលទទួលមរណភាពត្រូវទទួលប្រាក់ឧបត្ថម្ភផ្សេងៗដូចមន្ត្រីរាជការដែលដាក់ឱ្យចូលនិវត្តន៍ ហើយគ្រួសារសពត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចគ្រួសារសពជានិវត្តជនដែរ ។

ក្នុងករណីមានបណ្តាំរបស់សពអង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តតាមបណ្តាំ ។

**មាត្រា២៦.-** ចំពោះគ្រួសារសពអ្នករាជការ ត្រូវបានទទួលបើកប្រាក់សោធនិវត្តន៍ដែលបានកាត់ទុកក្នុងបេឡា ។

**មាត្រា២៧.-** អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិដែលកំពុងទទួលតំណែងជាអ្នកនយោបាយ នៅពេលចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានបើកផ្តល់ប្រាក់សោធនប្រចាំខែ ។

**មាត្រា២៨.-** អ្នករាជការដែលសុំឈប់ពីការងារហើយត្រូវប្រធានស្ថាប័នយល់ព្រមឱ្យឈប់ អ្នករាជការនោះត្រូវបានទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡា ។

**មាត្រា២៩.-** អ្នករាជការដែលត្រូវបញ្ឈប់ពីការងារដូចមានចែងក្នុងមាត្រា ៥១ និង មាត្រា ៦៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ត្រូវបានទទួលតែប្រាក់សោធននិវត្តន៍ដែលបានកាត់ទុកក្នុងបេឡាប៉ុណ្ណោះ ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា៣០.-** អគ្គលេខាធិការព្រឹទ្ធសភា អគ្គលេខាធិការរដ្ឋសភា និង អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលអនុវត្តឱ្យមានប្រសិទ្ធភាពនូវសេចក្តីសម្រេចនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ ២០០៧

| ប្រធានព្រឹទ្ធសភា | ប្រធានរដ្ឋសភា | ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ |
|---|---|---|
| ជា ស៊ីម | ហេង សំរិន | ឯក សំអុល |

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ដូចមាត្រា ៣០
- កាលប្បវត្តិ -ឯកសារ